អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

ប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានសំរេចក្នុងក្របខណ្ឌតម្លាភាពនិងយុត្តិធម៌បង្ហាញនូវលទ្ធផលនៃសវនកម្មពិសេសនៅខាងភាគីកម្ពុជានៃអ.វ.ត.កដែលបានធ្វើឡើងដោយអង្គការ UNDP រួមជាមួយនឹងការឆ្លើយតបខាងភាគីកម្ពុជា។

ក្នុងខណ:ពេលដែលសវនកម្មមិនត្រូវបានធ្វើឡើងជាសាធារណ:ខាងភាគីកម្ពុជានៃ អ.វ.ត.ក ដែលជាប្រធានបទនៃការធ្វើសវនកម្មនេះមានចេតនាក្នុងការបង្ហាញនូវរបាយការណ៍នេះដូចដែលអ្នកផ្តល់ជំនួយដល់អ.វ.ត.កធ្លាប់បានប្រាប់ជារឿយៗ។ ខុសប្លែកអំពីទស្សន:របស់អង្គការUNDP ដែលថារបាយការណ៍សវនកម្ម គឺជាឯកសារផ្ទៃក្នុង ប៉ុន្តែអង្គការនេះមិនបានអនុវត្តតាមទស្សន:របស់គេនោះទេរហូតដល់ពេលនេះ។

ក្នុងប៉ុន្មានសប្តាហ៍កន្លងមកនេះ ផ្នែកខ្លះនៃរបាយការណ៍ត្រូវបានលេចធ្លាយទៅដល់ប្រព័ន្ធផ្សព្វផ្សាយដែលប្រការនេះធ្វើឱ្យមានទស្សន:អវិជ្ជមាននិងប៉ះពាល់ដល់អ.វ.ត.ក។ លើសពីនេះទៅទៀតកាលពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៧ អង្គការUNDP បានសង្ខេបរបាយការណ៍សវនកម្មដាក់នៅក្នុងវិបសាយរបស់ខ្លួន។ ក្នុងកាល:ទេស:បែបបនេះយើងនឹងបង្ហាញជាសារធារណ:នូវរបាយការណ៍ទាំងមូលនៅក្នុងវិបសាយ របស់អ.វ.ត.ក (www.eccc.gov.kh) ដើម្បីបញ្ចប់នូវការពិចារណាផ្សេងៗគ្នា ដែលប៉ះពាល់ ទៅដល់ដំណើរការក្នុងការស្វែងរកយុត្តិធម៌។

ក្នុងច្បាប់ដើមរបស់ខ្លួន របាយការណ៍សវនកម្មបានរួមបញ្ចូលនូវការឆ្លើយតបរបស់ភាគីកម្ពុជាទៅក្នុងឧបសម្ព័ន្ធនានា។ សំរាប់ពេលនេះ យើងបានបញ្ចូលនូវការឆ្លើយតបទាំងនោះទៅក្នុងអត្ថបទទាំងស្រុងដើម្បីឱ្យអ្នកអានមានការងាយស្រួល និងដោយបានលុបចោលនូវឈ្មោះបុគ្គលិកដែលមានបញ្ហាក់នៅក្នុងរបាយការណ៍នោះ ហើយបានដាក់បន្ថែមនូវការធ្វើអត្ថាធិប្បាយសង្ខេបខ្លះៗនៅក្នុងការឆ្លើយតបដែលបានធ្វើឡើងភ្លាមៗទាន់ទៅតាមសភាពការណ៍ជាក់ស្តែង។

***សំរាប់ព័ត៌មានបន្ថែមសូមទាក់ទងបណ្ឌិត ហេឡិន ចារវីស ប្រធានផ្នែកកិច្ចការសាធារណ: នៃអ.វ.ត.ក តាមរយ:ទូរស័ព្ទលេខ (៨៥៥) ១២ ៤៨៨ ១៣៤ ៕***